# អ្នកកំពុងត្រូវបានព្យាបាលជំងឺបង្កដោយមេរោគចូលក្នុងឈាម (sepsis)

ជំងឺបង្កដោយមេរោគចូលក្នុងឈាម កើតឡើងនៅពេលដែលការឆ្លើយតបរបស់រាងកាយទៅនឹងមេរោគមួយដែលបំផ្លាញជាលិកា និងសរីរាង្គដែលមានសុខភាពល្អរបស់វា។ អ្នកបានឆ្លងមេរោគមួយ ដែលអាចបណ្តាលឱ្យកើតជំងឺបង្កដោយមេរោគចូលក្នុងឈាម។ ជំងឺបង្កដោយមេរោគចូលក្នុងឈាម គឺជាការសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្រ្ត ដែលត្រូវការការព្យាបាលផ្នែកវេជ្ជសាស្រ្តជាបន្ទាន់។

## តើជំងឺបង្កដោយមេរោគចូលក្នុងឈាមត្រូវបានព្យាបាលយ៉ាងដូចម្តេចដែរ?

ជំងឺបង្កដោយមេរោគចូលក្នុងឈាមត្រូវបានព្យាបាលនៅក្នុងមន្ទីរពេទ្យ ហើយការព្យាបាលមានប្រសិទ្ធភាពបំផុតនៅពេលចាប់ផ្តើមឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន។ មនុស្សមួយចំនួនដែលមានជំងឺបង្កដោយមេរោគចូលក្នុងឈាម ចាំបាច់ត្រូវការការព្យាបាលនៅក្នុងមន្ទីរព្យាបាលអ្នកជំងឺធ្ងន់ធ្ងរ ។

ការព្យាបាលរួមមានថ្នាំអង់ទីប៊ីយោទិច ហើយប្រសិនបើចាំបាច់៖

- ថ្នាំព្យាបាលផ្សេងទៀត
- ការចាក់បញ្ចូលសារធាតុរាវតាមសរសៃឈាម
- ជំនួយក្នុងការដកដង្ហើម
- ការវះកាត់។

## ជាសះស្បើយឡើងវិញ និងការចេញពីមន្ទីរពេទ្យ

មុនពេលអ្នកចេញពីមន្ទីរពេទ្យ ក្រុមថែទាំសុខភាពរបស់អ្នកនឹងពិនិត្យមើល៖

- ការជាសះស្បើយឡើងវិញរបស់អ្នក និងរយៈពេលដែលវាអាចនឹងត្រូវការ
- វិធីដើម្បីជៀសវាងការឆ្លងមេរោគ
- សញ្ញានានាដែលត្រូវឃ្លាំមើល ប្រសិនបើអ្នកមិនបានប្រសើរឡើងទេ ឬមានអារម្មណ៍កាន់តែអាក្រក់។
- ថ្នាំព្យាបាលរបស់អ្នក និងរបៀបលេបវាដោយសុវត្ថិភាព
- ផលប៉ះពាល់ និងការថែទាំរយៈពេលវែងណាមួយដែលអ្នកប្រហែលជាត្រូវការនៅពេលក្រោយ។

ប្រសិនបើអ្នកមានជំងឺបង្កដោយមេរោគចូលក្នុងឈាម អ្នកមានឱកាសខ្ពស់ក្នុងការកើតវាម្តងទៀត។ ប្រសិនបើអ្នកបារម្ភថារោគសញ្ញារបស់អ្នកកាន់តែអាក្រក់បន្ទាប់ពីអ្នកចេញពីមន្ទីរពេទ្យ សូមទូរសព្ទទៅ **13HEALTH** ដើម្បីទទួលបានដំបូន្មាន ជួប GP របស់អ្នក ឬត្រឡប់ទៅមន្ទីរពេទ្យវិញ។

## ផលប៉ះពាល់រយៈពេលវែង

ការជាសះស្បើយពីជំងឺបង្កដោយមេរោគចូលក្នុងឈាមត្រូវការពេលវេលា ហើយមនុស្សមួយចំនួនមានបញ្ហាយូរអង្វែង។ អ្នកប្រហែលជាមានអារម្មណ៍មិនស្រួលខ្លួនមួយរយៈ ឬពិបាកក្នុងការត្រឡប់ទៅធ្វើសកម្មភាពធម្មតាវិញ។ ប្រសិនបើអ្នកព្រួយបារម្ភ សូមពិគ្រោះជាមួយវេជ្ជបណ្ឌិត ឬក្រុមថែទាំសុខភាពរបស់អ្នកសម្រាប់ការគាំទ្រ។

ប្រព័ន្ធភាពស៊ាំរបស់អ្នកអាចនឹងចុះខ្សោយមួយរយៈ ដែលធ្វើឱ្យការឆ្លងមេរោគកាន់តែទំនងជាកើតមាន។ រក្សាបច្ចុប្បន្នភាពជាមួយការចាក់វ៉ាក់សាំង អនុវត្តអនាម័យល្អ និងសួរក្រុមថែទាំសុខភាពរបស់អ្នកអំពីការព្យាបាលដែលអាចជួយបាន។

## ការគាំទ្រក្នុងអំឡុងពេល និងក្រោយពេលកើតជំងឺបង្កដោយមេរោគចូលក្នុងឈាម

អនុញ្ញាតឱ្យក្រុមថែទាំសុខភាពរបស់អ្នកដឹង ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ឬមន្ត្រីទំនាក់ទំនងវប្បធម៌។

សូមមើលកូដ QR ខាងក្រោម ឬស្វែងរក Sepsis Australia (ជំងឺបង្កដោយមេរោគចូលក្នុងឈាមរបស់អូស្រ្តាលី) សម្រាប់ក្រុមគាំទ្រជំងឺបង្កដោយមេរោគចូលក្នុងឈាមដែលអាចជួយអ្នក និងគ្រួសាររបស់អ្នកក្នុងអំឡុងពេលជាសះស្បើយឡើងវិញ។

ស្កេនកូដ QR ប្រសិនបើអ្នកមានមតិកែលម្អណាមួយអំពីខិត្តប័ណ្ណព័ត៌មាននេះ។

ស្កេនកូដ QR ប្រសិនបើអ្នកមានមតិកែលម្អណាមួយអំពីខិត្តប័ណ្ណព័ត៌មាននេះ។

DELIVERING FOR QUEENSLAND

Queensland Government

SC26000479_V1.2 06/2026